# <u>សេចក្តីប្រកាសព័ត៌មាន</u>

## <u>ស្តីពី</u>

## កិច្ចប្រជុំលើកទី៧១ របស់គណៈកម្មាធិការអាស៊ាន ផ្នែកវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា (COST-71) កិច្ចប្រជុំក្រៅផ្លូវការលើកទី៩ ថ្នាក់រដ្ឋមន្ត្រីអាស៊ាន ផ្នែកវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា (IAMMST-9) និងកិច្ចប្រជុំពាក់ព័ន្ធ

ដោយបានការអនុញ្ញាតពីរាជរដ្ឋាភិបាលកម្ពុជា ក្រសួងឧស្សាហកម្ម និងសិប្បកម្ម ក្នុងនាមជាម្ចាស់ផ្ទះ បាន នឹងកំពុងរៀបចំកិច្ចប្រជុំលើកទី៧១ របស់គណៈកម្មាធិការអាស៊ាន ផ្នែកវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា (COST-71) កិច្ចប្រជុំក្រៅផ្លូវការលើកទី៩ ថ្នាក់រដ្ឋមន្ត្រីអាស៊ានផ្នែកវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា (IAMMST-9) និងកិច្ចប្រជុំអាស៊ានផ្នែកវិទ្យាសាស្ត្រ និងបច្ចេកវិទ្យាជាមួយដៃគូអភិវឌ្ឍ និងអង្គការអន្តរជាតិជាដៃគូមួយចំនួន (រួមមានអាស៊ាន-អាមេរិក អាស៊ាន-ជប៉ុន អង្គការ UNCTAD ជាដើម) ចាប់ពីថ្ងៃទី២៤ ដល់ថ្ងៃទី២៩ ខែតុលា ឆ្នាំ២០១៦ នៅសណ្ឋាគារ Apsara Palace Resort and Conference Center ទីក្រុងសៀមរាប នៃព្រះរាជាណាចក្រកម្ពុជា ។

កិច្ចប្រជុំដ៏មានសារៈសំខាន់នេះ បាន នឹងកំពុងប្រព្រឹត្តទៅដោយមានកិច្ចប្រជុំពាក់ព័ន្ធ ដែលមានការជជែកពិភាក្សាអំពីការងារផ្នែកវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា ទៅតាមផ្នែក តាមជំនាញ និងតាមវិស័យអាទិភាពរបស់អាស៊ាន ។

<u>**ថ្ងៃទី២៤ ខែតុលា ឆ្នាំ២០១៦**</u> មានកិច្ចប្រជុំអនុគណៈកម្មាធិការជំនាញចំនួន ៨រួមមាន៖

១. កិច្ចប្រជុំលើកទី៤៨ របស់អនុគណៈកម្មាធិការបច្ចេកវិទ្យាជីវៈសាស្ត្រ (Sub-Committee on Biotechnology-SCB-48)

២. កិច្ចប្រជុំលើកទី៤៩ របស់អនុគណៈកម្មាធិការហេដ្ឋារចនាសម្ព័ន្ធ និងអភិវឌ្ឍធនធានផ្នែកវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា (Sub-Committee on S&T Infrastructure and Human Resources Development-SCIRD-49)

៣. កិច្ចប្រជុំអនុគណៈកម្មាធិការវិទ្យាសាស្ត្រ និងបច្ចេកវិទ្យាលំហសមុទ្រ (Sub-Committee on Marine Science and Technology-SCMSAT)

៤. កិច្ចប្រជុំលើកទី៤៦ របស់អនុគណៈកម្មាធិការសម្ភារៈវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា (Sub-Committee on Material Science and Technology-SCMST-46)

៥. កិច្ចប្រជុំលើកទី៤៥ របស់អនុគណៈកម្មាធិការមីក្រូអេឡិចត្រូនិក និងបច្ចេកវិទ្យាព័ត៌មាន (Sub-Committee on Microelectronics and Information Technology-SCMIT-45)

៦. កិច្ចប្រជុំលើកទី៤៧ របស់អនុគណៈកម្មាធិការវិទ្យាសាស្ត្រ និងបច្ចេកវិទ្យាចំណីអាហារ (Sub-Committee on Food Science and Technology-SCFST-47)

៧. កិច្ចប្រជុំលើកទី៤៦ របស់អនុគណៈកម្មាធិការសិក្សាស្រាវជ្រាវថាមពលប្រកបដោយចេរភាព (Sub-Committee on Non-Conventional Energy Research-SCSER-46)

៨. កិច្ចប្រជុំលើកទី២៧ របស់អនុគណៈកម្មាធិការវិទ្យាសាស្ត្រ និងបច្ចេកវិទ្យាក្នុងលំហ និងការអនុវត្ត (Sub-Committee on Space Technology and Applications-SCOSA-27) ។

**ថ្ងៃទី២៥ ខែតុលា ឆ្នាំ២០១៦** មាន៖

កិច្ចប្រជុំលើកទី២ របស់ក្រុមប្រឹក្សាផ្តល់យោបល់ដល់គណៈកម្មាធិការអាស៊ានផ្នែកវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា (Board of Advisers to COST-BAC-2)

**ទី២៦ ខែតុលា ឆ្នាំ២០១៦** មាន៖

ពិធីបើកកិច្ចប្រជុំលើកទី៧១ របស់គណៈកម្មាធិការអាស៊ាន ផ្នែកវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា (COST-71)និងកិច្ចប្រជុំពាក់ព័ន្ធក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **ឯកឧត្តមបណ្ឌិត ចម ប្រសិទ្ធ ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី** ក្រសួងឧស្សាហកម្ម និងសិប្បកម្ម ។
ដំណើរការនៃកិច្ចប្រជុំនេះដឹកនាំដោយ **ឯកឧត្តមបណ្ឌិត ទឹម ស៊ីនី** អនុរដ្ឋលេខាធិការក្រសួងឧស្សាហកម្ម និងសិប្បកម្ម និងជាប្រធានគណៈកម្មាធិការអាស៊ាន ផ្នែកវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា ដែលនឹងធ្វើការពិនិត្យ និងសម្រេចទៅលើលទ្ធផលទទួលបានពីកិច្ចប្រជុំអនុគណៈកម្មាធិការជំនាញទាំង៨ ផ្នែកវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា និងក្រុមប្រឹក្សាផ្តល់យោបល់ដល់គណៈកម្មាធិការអាស៊ាន ផ្នែកវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា លើកទី២ (BAC-2) និងពិនិត្យ សម្រេចការងារសេសសល់ពីកិច្ចប្រជុំលើកមុន ។

**ទី២៧ ខែតុលា ឆ្នាំ២០១៦** មាន៖

– កិច្ចប្រជុំរបស់គណៈកម្មការរៀបចំសេចក្តីព្រាងលទ្ធផលនៃកិច្ចប្រជុំ COST-71
– កិច្ចប្រជុំលើកទី៦ របស់ដៃគូប្រឹក្សាយោបល់អាស៊ាន-អាមេរិក ផ្នែកវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា ដឹកនាំដោយ **ឯកឧត្តមបណ្ឌិត ទឹម ស៊ីនី** អនុរដ្ឋលេខាធិការក្រសួងឧស្សាហកម្ម និងសិប្បកម្ម និងជាប្រធានគណៈកម្មាធិការអាស៊ានផ្នែកវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា ។

**ទី២៨ ខែតុលា ឆ្នាំ២០១៦** មាន៖

- កិច្ចប្រជុំលើកទី៧ របស់គណៈកម្មការកិច្ចសហប្រតិបត្តិការអាស៊ាន-ជប៉ុន ផ្នែកវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា (AJCCST-7) ដឹកនាំដោយ **ឯកឧត្តមបណ្ឌិត ទឹម ស៊ីនី** អនុរដ្ឋលេខាធិការក្រសួងឧស្សាហកម្ម និងសិប្បកម្ម និងជាប្រធានគណៈកម្មាធិការអាស៊ាន ផ្នែកវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា ។
- ពិធីផ្តល់រង្វាន់ជ័យលាភីផ្នែកវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា ដល់ជ័យលាភីវ័យក្មេង និងស្ត្រី អ្នកស្រាវជ្រាវនៃប្រទេសសមាជិកអាស៊ាន ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **ឯកឧត្តមបណ្ឌិត ចម ប្រសិទ្ធ ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី** ក្រសួងឧស្សាហកម្ម និងសិប្បកម្ម ។

<u>**ទី២៩ ខែតុលា ឆ្នាំ២០១៦**</u> មានៈ

- ពិធីបើក និងដំណើរការកិច្ចប្រជុំក្រៅផ្លូវការលើកទី៩ ថ្នាក់រដ្ឋមន្ត្រីអាស៊ានផ្នែកវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា (IAMMST-9) ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **ឯកឧត្តមបណ្ឌិត ចម ប្រសិទ្ធ ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី** ក្រសួងឧស្សាហកម្ម និងសិប្បកម្ម ។
- កិច្ចប្រជុំទ្វេភាគីផ្នែកវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា រវាង **ឯកឧត្តមបណ្ឌិត ចម ប្រសិទ្ធ ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី** ក្រសួងឧស្សាហកម្ម និងសិប្បកម្មកម្ពុជា ជាមួយ **ឯកឧត្តម** Hor. Datuk Seri Panglima Madius Tangau **រដ្ឋមន្ត្រី** ក្រសួងវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ នៃប្រទេសម៉ាឡេស៊ី ។
- កិច្ចប្រជុំទ្វេភាគីផ្នែកវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា រវាង **ឯកឧត្តមបណ្ឌិត ចម ប្រសិទ្ធ ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី** ក្រសួងឧស្សាហកម្ម និងសិប្បកម្មកម្ពុជា ជាមួយ **ឯកឧត្តមបណ្ឌិត** Dr. Pichet Durongkaveroj **រដ្ឋមន្ត្រី** ក្រសួងវិទ្យាសាស្ត្រ បច្ចេកវិទ្យាប្រទេសថៃ ។

--------------------